# ស្ថានភាពសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរ និងយុទ្ធសាស្ត្រទប់ស្កាត់
# កាត់បន្ថយគ្រោះថ្នាក់ចរាចរផ្លូវគោក

## I-**សេចក្តីផ្តើម** :

មុនពេលមានសង្គ្រាមស៊ីវិល ប្រទេសកម្ពុជាមានច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដែលជាមូលដ្ឋានគតិយុត្តិសំរាប់គ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរនៅទូទាំងប្រទេស ។ ពេលនោះស្ថានភាពចរាចរបានប្រព្រឹត្តទៅមានលក្ខណៈល្អប្រសើរជាបង្គួរ អាស្រ័យដោយហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពាន តម្រូវការនៃការប្រើប្រាស់មធ្យោបាយយានយន្តគ្រប់ប្រភេទសមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ច និងបរិយាកាសសង្គមក្នុងដំណាក់កាលនោះ ។ ចាប់ពីឆ្នាំ១៩៧០ ប្រទេសជាតិបានធ្លាក់ចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាម ប្រព័ន្ធគម–នាគមន៍មួយចំនួនត្រូវកាត់ផ្តាច់ពីទីប្រជុំជនស្រុកមកខេត្ត និងពីទីរួមខេត្តមកទីក្រុងភ្នំពេញ ។ ប្រជាពលរដ្ឋបានប្រមូលផ្តុំមករស់នៅតាមទីប្រជុំជន ទីក្រុង ដែលជាការចាប់ផ្តើមធ្វើអោយស្ថានភាពចរាចរមានភាពស្មុគស្មាញ សណ្តាប់ធ្នាប់ចរាចរណ៍ត្រូវបានបាត់បង់ជាបណ្តើរៗ អាត្រានៃគ្រោះថ្នាក់ចរាចរណ៍ក៏មានកំណើនជាបន្តបន្ទាប់ ។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពានមួយចំនួនក៏ត្រូវបានខ្ទេចខ្ទាំដោយសារសង្គ្រាម និងខូចខាតដោយសារការមិនបានជួសជុលថែទាំ ។

ក្រោយឆ្នាំ១៩៧៩ ការស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពានត្រូវបានគិតគូរឡើងវិញ បំរើបានតម្រូវការដឹកជញ្ជូន អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងធ្វើអោយប្រសើរឡើងនូវសុខមាលភាព និងការរស់នៅរបស់ប្រជាពលរដ្ឋ ។ ច្បាប់ស្តីពីចរាចរផ្លូវគោកត្រូវបានតាក់តែងឡើងវិញ និងប្រកាសអោយប្រើប្រាស់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩១ ។ អនុលោមតាមច្បាប់នេះក្រសួងមហាផ្ទៃ ក្រសួងសាធារណៈការនិងដឹកជញ្ជូន និងអាជ្ញាធរមានសមត្ថកិច្ច បានរៀបចំនូវលិខិតបទដ្ឋានជាច្រើនសំដៅពង្រឹងគ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរផ្លូវគោកអោយកាន់តែល្អប្រសើរ ។ ប៉ុន្តែអាស្រ័យដោយសេដ្ឋកិច្ចជាតិមានការរីកចំរើនឆាប់រហ័ស ស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋត្រូវបានលើកកំពស់តម្រូវការផ្សេងៗក្នុងសង្គមកាន់តែមានកំរិតខ្ពស់ ជាពិសេសតម្រូវការក្នុងការប្រើប្រាស់មធ្យោបាយយានយន្តគិតទាំងស្ថាប័នរដ្ឋ សង្គមស៊ីវិល និងឯកជន បានធ្វើអោយមានការប្រែប្រួលយ៉ាងខ្លាំងអំពីស្ថានភាពសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរ ដែលជាហេតុធ្វើអោយជះឥទ្ធិពលដល់ទិដ្ឋភាពនានាជាច្រើន មានន័យថា មិនត្រឹមតែធ្វើអោយស្លាប់ និងរបួសមនុស្សជាប្រចាំថ្ងៃនោះទេ ប៉ុន្តែក៏បានធ្វើអោយខាតបង់ធនធានសេដ្ឋកិច្ច ប៉ះពាល់ដល់នយោបាយកាត់បន្ថយភាពក្រីក្រ និងធ្វើអោយប៉ះពាល់ដល់កិត្យានុភាព និងភាពថ្លៃថ្នូររបស់ជាតិមួយថែមទៀត ។

មិនត្រឹមតែក្របខ័ណ្ឌកម្ពុជាមួយប៉ុណ្ណោះទេ ប៉ុន្តែស្ថានភាព និងសុវត្ថិភាពចរាចរក្នុងពិភពលោក និងតំបន់នាពេលបច្ចុប្បន្នក៏បានធ្វើអោយមានការចាប់អារម្មណ៍យ៉ាងខ្លាំង សិក្ខាសាលាលើកទី១ ស្តីពីដៃគូសុវត្ថិភាពផ្លូវគោកជាសកលនៅបណ្តាប្រទេសអាស៊ាន (GRSP) បានប្រារព្ធធ្វើឡើងកាលពីថ្ងៃទី២៦-២៨ ខែមិនា ឆ្នាំ២០០១ នៅទីក្រុងតូក្យូ ដែលមានប្រទេសជាសមាជិកអាស៊ានទាំង ១០ និងបណ្តាអង្គការនានាចំនួន ១១ ចូលរួម ដើម្បីពិគ្រោះយោបល់ដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងការកាត់បន្ថយអាត្រាគ្រោះថ្នាក់ចរាចរនៅក្នុងតំបន់របស់យើងនេះ ។ នៅខែមករា ឆ្នាំ២០០៤ នាទីក្រុងភ្នំពេញ ក្រោមជំនួយឧបត្ថម្ភរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបើកសិក្ខាសាលាមួយស្តីពីសកម្មភាពសុវត្ថិភាពផ្លូវគោក ហើយគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើង ដែលមានតួនាទីរៀបចំគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសុវត្ថិភាពចរាចរផ្លូវគោកអោយមានប្រសិទ្ធិភាព ។

## II-<u>**គោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរផ្លូវគោក**</u> :

### ១-<u>**គោលនយោបាយជាតិ**</u> :

ស្របតាមយុទ្ធសាស្ត្រចតុកោណ ក៏ដូចជាគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្នក៏វិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការរីកចំរើនជាលំដាប់ ។ ក៏វិតជីវភាពរស់នៅមានការរីកចំរើន មធ្យោបាយធ្វើដំណើរក៏មានការកើនឡើងគួរអោយកត់សម្គាល់ ក្នុងនោះបញ្ហាសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរគឺជាបញ្ហាមួយយ៉ាងសំខាន់ដែលត្រូវបានយកចិត្តទុកដាក់ និងចាប់អារម្មណ៍ ។ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពគ្រោះថ្នាក់ចរាចរនាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលមានគោលនយោបាយសុវត្ថិភាពចរាចរផ្លូវគោក ដើម្បីកាត់បន្ថយអាត្រាគ្រោះថ្នាក់ចរាចរ រៀបចំសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរ សំដៅកាត់បន្ថយការបាត់បង់ថវិកាជាតិដោយសារគ្រោះថ្នាក់ចរាចរ ការខូចខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជន ព្រមទាំងកាត់បន្ថយនូវផលវិបាកសង្គម ដូចជាការបន្សល់ទុកនូវកុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ និងទុរគតភាព ។

ក្នុងក្របខ័ណ្ឌគោលនយោបាយខាងលើនេះ គំរោងកម្មវិធីសុវត្ថិភាពលើដងផ្លូវគឺសំដៅពង្រឹងសមត្ថភាពនៅតាមស្ថាប័ន តាមរយៈការបណ្តុះបណ្តាល ការរៀបចំធ្វើឯកសារ បទដ្ឋាននានាដែលពាក់ព័ន្ធបច្ចេកទេស រៀបចំបណ្តាញការងារ និងការផ្លាស់ប្តូរពិសោធន៍រវាងបណ្តាប្រទេសក្នុងតំបន់ ។ លើមូលដ្ឋាននេះទាមទារប្រមូលផ្តុំរាល់កម្លាំងទាំងអស់ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលរវាងគ្រប់ស្ថាប័ន អង្គការនានា វិស័យឯកជន និងសាធារណៈជនទាំងអស់ដើម្បីចាត់វិធានការកែលំអរសុវត្ថិភាពលើដងផ្លូវ ។

**២.ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចរាចរផ្លូវគោក :**

ក្រសួងចំនួនពីរ ដើរតួនាទីសំខាន់ក្នុងការធ្វើសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរ គឺក្រសួងមហាផ្ទៃ និងក្រសួងសាធារណៈការ និងដឹកជញ្ជូន ។

–ក្រសួងមហាផ្ទៃ មានភារកិច្ចរៀបចំចាត់ចែងសណ្តាប់ធ្នាប់ សុវត្ថិភាពលើដងផ្លូវ និងកិច្ចប្រតិបត្តិការអនុវត្តច្បាប់ (និយាយដោយឡែកលើការងារចរាចរផ្លូវគោក) ។

–ក្រសួងសាធារណៈការ និងដឹកជញ្ជូន មានភារកិច្ចគ្រប់គ្រងការងារដឹកជញ្ជូន ការគ្រប់គ្រងជួសជុល ថែរក្សា និងអភិវឌ្ឍន៍ផ្លូវ ស្ពាន គ្រប់គ្រងការធ្វើអាជីវកម្មយានយន្ត និងសាលារៀនបើកបរឯកជន ។

–បន្ថែមពីលើក្រសួងទាំងពីរនេះ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥ មានតួនាទីកំណត់អំពីនយោបាយជាតិលើសកម្មភាពសុវត្ថិភាពចរាចរផ្លូវគោក ។

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ ការងារចុះបញ្ជីផ្តល់ប័ណ្ណសំគាល់យានយន្តគ្រប់ប្រភេទ និងការត្រួតពិនិត្យផ្តល់ប័ណ្ណបើកបរជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។ រហូតដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៨៩ ក្រសួងមហាផ្ទៃ និងក្រសួងគមនាគមន៍និងប្រៃសណីយ៍ (បច្ចុប្បន្នក្រសួងសាធារណៈការ និងដឹកជញ្ជូន) បានចេញសេចក្តីប្រកាសរួម ដោយផ្ទេរភារកិច្ចការងារចុះបញ្ជីផ្តល់ប័ណ្ណសំគាល់យានយន្តគ្រប់ប្រភេទ និងផ្តល់ប័ណ្ណបើកបរជាសមត្ថកិច្ចរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូនវិញ ។ ដោយឡែកក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ទទួលខុសត្រូវចុះបញ្ជីផ្តល់ប័ណ្ណសំគាល់យានយន្តគ្រប់ប្រភេទជាទ្រព្យសម្បត្តិរដ្ឋ ក្រោមការគ្រប់គ្រងរបស់ក្រសួងទាំងពីរ ។

ក្រោមជំនួយបច្ចេកទេសពីរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ការចុះបញ្ជីផ្តល់ប័ណ្ណសំគាល់យានយន្តបានដំណើរការតាមប្រព័ន្ធព័ត៌មានវិទ្យា ដោយបញ្ចូលនូវអត្តសញ្ញាណ និងរាល់ទិន្នន័យបច្ចេកទេសរបស់យានយន្តនិមួយៗ ។ តាមរយៈប្រព័ន្ធការងារនេះបានបង្កលក្ខណៈងាយស្រួលដល់ការចុះបញ្ជីគ្រប់គ្រង និងការចែកចាយទិន្នន័យ ។ ប៉ុន្តែនៅក្នុងដំណាក់កាលនៃការអនុវត្តក៏មានកង្វះខាតខ្លះក្នុងកិច្ចសហការ មានការយឺតយ៉ាវក្នុងការផ្តល់ទិន្នន័យយានយន្តមកក្រសួងមហាផ្ទៃ ដោយទើបតែបានកែសំរួលក្នុងពេលថ្មីៗកន្លងមកនេះ ។ បញ្ហានេះក៏បានធ្វើអោយមានការជះឥទ្ធិពលដល់ការគ្រប់គ្រង ការងារស្រាវជ្រាវករណីគ្រោះថ្នាក់ចរាចរ ស្រាវជ្រាវបទល្មើសផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់យានយន្ត ក៏ដូចជាការសិក្សាស្រាវជ្រាវផ្សេងៗពាក់ព័ន្ធទៅនឹងការរៀបចំសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរ ។

ចំពោះការផ្តល់ប័ណ្ណបើកបរយានយន្តមកទល់បច្ចុប្បន្ននេះ មានសាលារៀនបើកបរឯកជនចំនួន**១១** មានស្នាក់ការតាំងនៅ **០៧ខេត្ត–ក្រុង** ត្រូវបានអនុញ្ញាតិច្បាប់អោយបើកបង្រៀនបើកបរយានយន្ត ។ ពីឆ្នាំ១៩៩០ មកដល់ឆ្នាំ២០០៥នេះ បានផ្តល់ប័ណ្ណបើកបរដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទបានចំនួន

**២៨០.៦៤៥នាក់** ។ ទោះបីយ៉ាងនេះយើងក៏បានពិនិត្យឃើញថា ការបង្រៀនបើកបរមិនទាន់ធានាបានតាមកំរិតស្តង់ដារ ការត្រួតពិនិត្យប្រឡងផ្តល់ប័ណ្ណបើកបរក៏នៅមានភាពធូររលុងដោយអន្លើ ។

ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរផ្លូវគោក ច្បាប់ស្តីពីចរាចរផ្លូវគោកត្រូវបានដាក់អោយប្រើប្រាស់កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩១ ។ ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងមហាផ្ទៃ បានរៀបចំលិខិតបទដ្ឋានមួយចំនួនបន្ថែមទៀតមានជាអាទិ៍ :

-អនុក្រិត្យស្តីពីការផ្តល់ប័ណ្ណសំគាល់យានយន្តផ្លូវគោក

-អនុក្រិត្យស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវថ្នល់ និងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា

-អនុក្រិត្យស្តីពីការកំរិតទម្ងន់អតិបរមានៃយានយន្តដឹកទំនិញផ្លូវគោក

-បទដ្ឋានគំរូបច្ចេកទេសជំហានដំបូងនៃគំនូរស្តង់ដារសម្ភារៈ និងផ្នែកចរាចរ

-ប្រកាសអន្តរក្រសួងមហាផ្ទៃ សាធារណៈការនិងដឹកជញ្ជូន សុខាភិបាល ស្តីពីការស្រង់ទិន្នន័យគ្រោះថ្នាក់ចរាចរ ។ល។

ផ្អែកតាមការវិវឌ្ឍន៍រីកចំរើនរបស់សង្គម និងដើម្បីអោយច្បាប់ចរាចរផ្លូវគោកស្របតាមបទដ្ឋានបច្ចេកទេសក្នុងតំបន់ផងនោះ សេចក្តីព្រាងច្បាប់ថ្មីមួយត្រូវបានគណៈរដ្ឋមន្ត្រីពិនិត្យសំរេច និងបច្ចុប្បន្នកំពុងឆ្លងដោយគណៈកម្មាធិការទី៩ របស់រដ្ឋសភា ។

## III-ស្ថានភាពចរាចរផ្លូវគោកនៅព្រះរាជាណាចក្រកម្ពុជា :

### ១-ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពាន :

ហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពានគឺជាសរសៃឈាមនៃខឿនសេដ្ឋកិច្ចជាតិ ។ ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ផ្លូវថ្នល់សំខាន់ៗដែលក្រាលថ្ម ចាក់កៅស៊ូ ទាំងផ្លូវជាតិ និងផ្លូវខេត្ត មានប្រមាណតែជាង **២.១០០គ.មតែប៉ុណ្ណោះ** ក្រៅពីនេះភាគច្រើនជាប្រភេទផ្លូវក្រាលថ្ម និងក្រាលគ្រួសក្រហម ។ ផ្លូវប្រហែល **២០%** មានគុណភាពអន់ និងខ្វះភាពរឹងមាំ និង **៤០%**ទៀតជាផ្លូវលំតូចជាង ៤ម៉ែត្រ ។

ប៉ុន្តែរហូតមកទល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានបង្កើនល្បឿនជួសជុល និងស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធស្ពានផ្លូវទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ បំរើបានតម្រូវការដឹកជញ្ជូនអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ លើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជាជននៅទូទាំងប្រទេស ។ ជាមួយការជួយឧបត្ថម្ភពីបណ្តាប្រទេសជាមិត្ត ដែលបានផ្តល់ជំនួយឥតសំណង និងប្រាក់កម្ចី គួបផ្សំជាមួយធនធនជាតិ គិតមកទល់ពេលនេះការកសាងជួសជុល និងស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពាន ដាក់អោយដំណើរការចរាចរបានស្រួលសរុបប្រវែង **៣៥.៤៣២,៩៨១គ.ម** ក្នុងនោះរួមមាន :

-ផ្លូវជាតិលេខ ១-២-៣-៤-៥-៦-៧ មានប្រវែង **២.១១៥,៥២៦គ.ម**

-ផ្លូវជាតិផ្សេងទៀត មានប្រវែង **២.៦៩៣,៤៧៦គ.ម**

-ផ្លូវខេត្ត-ក្រុង មានប្រវែង **៦.៦៤៥,០៦៩គ.ម**

-ផ្លូវក្រាលគ្រួសក្រហម មានប្រវែង **៩.៤០២,៩១គ.ម**

-ផ្លូវដីធម្មតា មានប្រវែង **១៤.៥៧៦គ.ម**

ក្រៅពីផ្លូវថ្នល់បានជួសជុល និងកសាងស្ពានថ្មីចំនួន **២.២៣២កន្លែង** មានប្រវែងសរុប **៥២,៧៧២គ.ម** ។

## ២-ស្ថានភាពមធ្យោបាយយានយន្ត :

ស្របទៅនឹងការរីកចំរើនលើវិស័យសេដ្ឋកិច្ច តម្រូវការផ្សេងៗក្នុងសង្គមក៏មានកំរិតកើនឡើង ជាពិសេសមធ្យោបាយយានយន្តគ្រប់ប្រភេទមានកំណើនគួរអោយកត់សម្គាល់ ដែលជាក្រិតក្រមរ្យកើតមាននៅគ្រប់ប្រទេសកំពុងអភិវឌ្ឍន៍ ។

យោងតាមតួលេខនៃការចុះបញ្ជីយានយន្ត បានបង្ហាញអោយឃើញនូវកំណើនយានយន្តប្រមាណ **១០%** ជារៀងរាល់ឆ្នាំ គិតពីឆ្នាំ១៩៩៤ ដល់ទល់ឆ្នាំ២០០៤ និងបានកើនឡើងទ្វេរដង **២០,៤៥%** ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៥ ។

អាស្រ័យដោយលក្ខណៈពិសេសសភាពការណ៍នៅកម្ពុជា ប្រភេទគុណភាពយានយន្តដែលបាននាំចូលពីបរទេស និងដែលបាននិងកំពុងចរាចរនៅលើដងផ្លូវមានបីប្រភេទគឺ យានយន្តប្រភេទថ្មី យានយន្តជជុះ និងយានយន្តកែច្នៃ ចំពោះរថយន្តគ្រប់ប្រភេទក៏មាននាំចូលរថយន្តចង្កូតស្តាំផងដែរ ដែលផ្ទុយនឹងប្រព័ន្ធបើកបរប្រកាន់ស្តាំ ។ ប្រភេទយានយន្តជជុះ និងរថយន្តចង្កូតស្តាំដែលបានកែមកចង្កូតឆ្វេង គឺជាមធ្យោបាយដែលយើងមានការចាប់អារម្មណ៍ខ្លាំងលើផ្នែកសុវត្ថិភាពបច្ចេកទេស ។

គិតពីឆ្នាំ១៩៩០ មកទល់ឆ្នាំ២០០៥នេះ មធ្យោបាយយានយន្តគ្រប់ប្រភេទដែលបានចុះបញ្ជីនៅក្រសួងសាធារណៈការ និងដឹកជញ្ជូនមានចំនួន និងទិន្នន័យដូចខាងក្រោម :

-ទោចក្រយានយន្ត ចំនួន **៤២៩,៦៨៩គ្រឿង**

-រថយន្តធុនស្រាល ចំនួន **៨៧,៨៨៧គ្រឿង**

-រថយន្តដឹកអ្នកដំណើរ ចំនួន **១៣,០៧៧គ្រឿង**

-រថយន្តដឹកទំនិញ ចំនួន **៤៤,១៧៦គ្រឿង**

➢ក្នុងចំនួនរថយន្តគ្រប់ប្រភេទ តាមការប៉ាន់ប្រមាណមានរថយន្តចង្កូតស្តាំប្រហែល **១០%** ។

ដោយឡែកមធ្យោបាយយានយន្តដែលគ្រប់គ្រងដោយក្រសួងមហាផ្ទៃរួមមាន :

-ទោចក្រយានយន្ត ចំនួន **៤៤៣គ្រឿង**

-រថយន្តធុនស្រាល ចំនួន **១២៤គ្រឿង**

-រថយន្តដឹកកម្លាំង ចំនួន **១៧គ្រឿង**

ក្រៅពីមធ្យោបាយខាងលើនេះ មានយានយន្តកែឆ្នៃក្នុងស្រុកជាច្រើនទៀត ជាប្រភេទយានយន្តដឹកជញ្ជូន គោយន្ត រឺម៉ករុញ រឺម៉កម៉ូតូ ក៏មានកំណើនជាបន្តបន្ទាប់ ដែលមិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងចុះបញ្ជីគ្រប់គ្រងនៅឡើយ ។

## IV-**សភាពការណ៍សណ្តាប់ធ្នាប់សុវត្ថិភាពចរាចរផ្លូវគោក :**

ការអភិវឌ្ឍន៍កាន់តែប្រសើរឡើងនៃស្ថានភាពផ្លូវស្ពានទូទាំងប្រទេសតាំងពីទីក្រុងរហូតដល់ជនបទបានបង្កភាពងាយស្រួលដល់ដំណើរការធ្វើចរាចរដឹកជញ្ជូន បំរើតម្រូវការទាន់ពេលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិអោយមានការរីកចំរើន និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយចាកផុតពីទុរគតភាព ។ ជាមួយការងាយស្រួលនៃស្ថានភាពផ្លូវថ្នល់ និងកំណើនយ៉ាងឆាប់រហ័សនៃមធ្យោបាយយានយន្តគ្រប់ប្រភេទគួបផ្សំនឹងការប្រើប្រាស់ផ្លូវដោយមិនគោរពច្បាប់អោយបានម៉ឺងម៉ាត់ បានធ្វើអោយគ្រោះថ្នាក់ចរាចរមានការកើនឡើងជាបន្តបន្ទាប់គួរអោយកត់សំគាល់ ។

សណ្តាប់ធ្នាប់ចរាចរមានចំណងទាក់ទំនង និងជះឥទ្ធិពលដោយផ្ទាល់ដល់សុវត្ថិភាពចរាចរ ។ បើប្រសិនសណ្តាប់ធ្នាប់ចរាចរត្រូវបានបាត់បង់នោះនឹងធ្វើអោយគ្រោះថ្នាក់ចរាចរមានអាត្រាកាន់តែខ្ពស់ ។ សណ្តាប់ធ្នាប់ចរាចរមានការពាក់ព័ន្ធយ៉ាងច្រើនដល់អ្នកដែលប្រើប្រាស់ផ្លូវ ពាក់ព័ន្ធដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ បញ្ហាបរិស្ថាន និងកត្តាគួបផ្សំផ្សេងៗជាច្រើនទៀត ។

យោងតាមទិន្នន័យដែលប្រមូលបានគ្រប់គ្រាន់ជាបង្គួរចាប់តាំងពីឆ្នាំ ២០០០ រហូតដល់ឆ្នាំ ២០០៥ អាត្រាគ្រោះថ្នាក់ចរាចរមានការកើនឡើង **១៥%** ជារៀងរាល់ឆ្នាំ ដែលគិតជាមធ្យម**១ថ្ងៃ** មានមនុស្សស្លាប់ដោយគ្រោះថ្នាក់ចរាចរចំនួន **០៣នាក់** និងរបួស **២០នាក់** ។ ទោះបីក្នុងឆ្នាំ២០០៥ គ្រោះថ្នាក់ចរាចរមានការថយចុះ **៧%** បើប្រៀបធៀបទៅឆ្នាំ២០០៤ ក៏អាត្រាមនុស្សស្លាប់ និងរបួសនៅមានចំនួនច្រើននៅឡើយ ។ គិតនៅក្នុងសរុបទូវយានយន្ត **១០,០០០គ្រឿង** មានអាត្រាមនុស្សស្លាប់ **១៥,៧៣នាក់** (គិតក្នុងឆ្នាំ២០០៥) (ជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ និង២) ។ ទោចក្រយានយន្តគឺជាមធ្យោបាយដែលបង្កអោយមានគ្រោះថ្នាក់ច្រើន និងកើតមានរហូតដល់ **៦២%** និងបណ្តាលអោយមនុស្សរងគ្រោះរហូតដល់ **៧២%** ។

គ្រោះថ្នាក់ចរាចរមិនត្រឹមតែធ្វើអោយគ្រោះថ្នាក់ដល់អាយុជីវិត របួសមនុស្ស សត្វ និងបាត់បង់ទ្រព្យសម្បត្តិរដ្ឋ ឯកជនប៉ុណ្ណោះទេ ប៉ុន្តែបានធ្វើអោយប៉ះពាល់ និងខាតបង់ប្រភពធនធានសេដ្ឋកិច្ចដែលជាឧបសគ្គក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមថែមទៀត ។ យោងតាមការប្រមូលទិន្នន័យពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបង្ហាញអោយឃើញថាការខាតបង់បណ្តាលមកពីគ្រោះថ្នាក់ចរាចរក្នុងឆ្នាំ២០០៣ មានប្រមាណ **១១៦លានដុល្លាសហរដ្ឋអាមេរិក** ក្នុងឆ្នាំ២០០៤មានប្រមាណ **១៣១លានដុល្លាសហរដ្ឋអាមេរិក** និងមានប្រមាណ **១២២លានដុល្លាសហរដ្ឋអាមេរិក** ក្នុងឆ្នាំ២០០៥នេះ ។

## V-<u>សិក្សាអំពីមូលហេតុនៃគ្រោះថ្នាក់ចរាចរ</u> :

ដូចក្នុងទិន្នន័យដែលបានជំរាបជូនខាងលើ ពីមួយឆ្នាំទៅមួយឆ្នាំការបាត់បង់សណ្តាប់ធ្នាប់ចរាចរ និងករណីគ្រោះថ្នាក់ចរាចរមានការកើនឡើងគួរអោយព្រួយបារម្ភ ទោះបីមានការខិតខំប្រឹងប្រែងរៀបចំការពារ និងទប់ស្កាត់ពីសំណាក់នគរបាលចរាចរ និងភ្នាក់ងារមានសមត្ថកិច្ចរក្សាសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរយ៉ាងណាក៏ដោយ ចំនួននៃគ្រោះថ្នាក់ និងបញ្ហាកកស្ទះចរាចរក៏នៅកើតឡើងជាបន្តបន្ទាប់ ។

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ និងប្រមែប្រមូលទិន្នន័យ ការបាត់បង់សុវត្ថិភាពចរាចរ និងភាពងាយបង្កអោយមានគ្រោះថ្នាក់ចរាចរ បណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចខាងក្រោម :

### ១-<u>អំពីកត្តាច្បាប់ ការអនុវត្តច្បាប់ និងការផ្សព្វផ្សាយអប់រំ</u> :

-ច្បាប់ចរាចរផ្លូវគោកដែលបានដាក់ជាធរមាននៅឆ្នាំ១៩៩១ មានការខ្វះខាតនូវខ្លឹមសារសំខាន់ៗមួយចំនួន សំរាប់ជាបញ្ញាត្តិអោយអ្នកបើកបរអនុវត្តតាម ក៏ដូចជាដើម្បីរក្សាសុវត្ថិភាពក្នុងពេលបើកបរ ជាពិសេសទណ្ឌកម្មដែលមានចែងក្នុងបញ្ញត្តិច្បាប់មានកំរិតទាប ដែលធ្វើអោយអ្នកប្រព្រឹត្តមិនខ្លាចរអាក្នុងការធ្វើអោយមានកំហុស ។

-ការអនុវត្តន៏ច្បាប់របស់ភ្នាក់ងារអនុវត្តច្បាប់ដែលមានការពាក់ព័ន្ធនៅមានភាពធូររលុង និងអសកម្មជាច្រើន ដោយផ្អែកលើលក្ខ័ណ្ឌជីវភាព គួបផ្សំនឹងកង្វះខាតលើសម្ភារៈឧបករណ៏ទំនើបសំរាប់បំពេញភារកិច្ចត្រួតពិនិត្យសុវត្ថិភាព សណ្តាប់ធ្នាប់ចរាចរ ។ សមត្ថភាពយល់ដឹងអំពីច្បាប់របស់ភ្នាក់ងារអនុវត្តច្បាប់នៅមានកំរិត និងនៅមិនទាន់បានលើកកំពស់សីលធម៌ អាកប្បកិរិយាម៉ឺងម៉ាត់ក្នុងការបំពេញភារកិច្ច ដែលជាហេតុធ្វើអោយការគោរពច្បាប់របស់អ្នកប្រើប្រាស់ផ្លូវថ្នល់មានភាពទន់ខ្សោយ ។

-ការផ្សព្វផ្សាយអប់រំអំពីច្បាប់មានសារៈសំខាន់ ដើម្បីអោយមានការយល់ដឹង និងគោរពច្បាប់ជាទូទៅ ប៉ុន្តែកិច្ចការនេះយើងបានធ្វើតិចតួចបំផុត ហើយធ្វើបានតែនៅក្នុងទីក្រុងតែប៉ុណ្ណោះ ។ ការផ្សព្វផ្សាយអប់រំត្រូវធ្វើអោយទូលំទូលាយ គ្រប់បណ្តាញផ្សព្វផ្សាយតាំងពីក្នុងគ្រឹះស្ថានសិក្សា នៅក្នុងសហគមន៏ នៅក្នុងសង្គមគ្រួសារ ដើម្បីអោយមនុស្សម្នាក់ៗយល់ និងជួយអប់រំគ្នាទៅវិញទៅមក ។

### ២-<u>កត្តាអ្នកបើកបរ</u> :

-អ្នកប្រើប្រាស់ផ្លូវជាមុខសញ្ញាមួយសំខាន់បំផុតក្នុងការបង្កអោយមានគ្រោះថ្នាក់ចរាចរ ការបំពានច្បាប់របស់អ្នកប្រើប្រាស់ផ្លូវនៅតែមានរហូតដល់ **៩០.៧៥%** ។ អ្នកបើកបរមានប័ណ្ណបើកបរចំនួន **២៨០,៦៤៥នាក់** ។ អ្នកបើកបរមិនគោរពសិទ្ធិអាទិភាព មិនគោរពផ្លាកសញ្ញា ភ្លើងសញ្ញា បើកបរលើសល្បឿន បើកបរក្នុងស្ថានភាពស្រវឹង មិនប្រកាន់ស្តាំ ឆ្លងកាត់ខ្វះការប្រុងប្រយ័ត្ន ។ល។ អ្នកអូសរទេះ និងរុញរទេះ ដឹកសត្វ អ្នកថ្មើរជើង ការដង្ហែរក្បួនគ្មានច្បាប់ទម្លាប់នៅលើដងផ្លូវក៏បានរំខានដល់ការធ្វើចរាចរលើផ្លូវថ្នល់យ៉ាងខ្លាំងក្លាដែរ និងបង្កអោយគ្រោះថ្នាក់ជាញឹកញាប់ ។ ជាមួយគ្នានេះការបើកបរ

ក្នុងអកប្បកិរិយាខ្វះសីលធម៌ ខ្វះភាពយោគយល់ ការប្រណាំងយានយន្តខុសច្បាប់ក្នុងសភាពភ្លើតភ្លើនក៏បានបង្កអោយមានគ្រោះថ្នាក់ដល់ជនស្លូតត្រង់ជាទៃទៀត ។

**៣-កត្តាយានយន្ត :**

-យានយន្តមួយចំនួនកំពុងធ្វើចរាចរលើដងផ្លូវថ្នល់ពុំមានចុះបញ្ជី ពាក់ផ្លាកលេខតាមច្បាប់កំណត់នៅឡើយ យានយន្តខ្លះពាក់ផ្លាកលេខក្លែងក្លាយ ផ្លាកលេខមិនប្រក្រតី ហើយប្រភេទយានយន្តទាំងនេះដែលបង្កអោយមានការបាត់បង់សណ្តាប់ធ្នាប់ច្រើន ព្រមទាំងទាក់ទងដល់វិធានការការពារសន្តិសុខថែមទៀត ។

ទោចក្រយានយន្ត និងរថយន្តដឹកអ្នកដំណើរ ដឹកទំនិញខ្លះទៀត កែឆ្នៃតួ ទ្រុង ទំហំកំពស់ដោយគ្មានការអនុញ្ញាតិប្លង់ បច្ចេកទេស និងច្បាប់ពីក្រសួងជំនាញ ធ្វើអោយការកែឆ្នៃ និងដឹកជញ្ជូនខ្វះសុវត្ថិភាពជាដើម ។ ទន្ទឹមនឹងនេះការត្រួតពិនិត្យលក្ខណៈសុវត្ថិភាពបច្ចេកទេស គ្រាន់តែមានការត្រួតពិនិត្យតែមិនបានកំណត់ និងបង្ខំអោយម្ចាស់យានយន្តត្រូវតែកែលំអរ ជួសជុល ដើម្បីរក្សាសុវត្ថិភាពនៅឡើយ មានរថយន្តតែ **៩៤,៩៧០គ្រឿង**ប៉ុណ្ណោះ ដែលបានមកត្រួតពិនិត្យលក្ខណៈបច្ចេកទេស ។ ការដឹកអ្នកដំណើរហួសកំណត់ ជាពិសេសការត្រួតពិនិត្យទម្ងន់ផ្ទុករបស់រថយន្ត យើងបានបង្កើតគណៈកម្មការចំរុះដើម្បីត្រួតពិនិត្យ លើការដាក់ស្លែងគ្រាន់តែធ្វើការផាកពិន័យការផ្ទុកទំនិញលើសទម្ងន់ ប៉ុន្តែរថយន្តដែលផ្ទុកលើសទម្ងន់នៅតែអាចបន្តការធ្វើចរាចរលើដងផ្លូវថ្នល់បានដដែលបន្ទាប់ពីការផាកពិន័យ ចំណុចនេះចាំបាច់ត្រូវមានការកែសំរួលឡើងវិញ ។

**៤-កត្តាហេដ្ឋារចនាសម្ព័ន្ធ :**

-ហេដ្ឋារចនាសម្ព័ន្ធស្ពានថ្នល់ មកទល់បច្ចុប្បន្នបានពង្រីកទទឹងផ្លូវធំជាង ១ទ្វេរជា ២ដង និងមានលក្ខណៈបច្ចេកទេសជាស្តង់ដារបានល្អប្រសើរ ។ ប៉ុន្តែក៏នៅមានផ្លូវស្ពាន ដែលបាននិងកំពុងស្តារជួសជុលថែទាំ និងស្ពានបាក់ស្រុតនោះមួយចំនួននៅតូចចង្អៀត កោង និងផ្លូវមួយចំនួនកំពុងឈានទៅខូចខាត និងទ្រុឌទ្រោមទៅវិញបើមិនមានការថែទាំជួសជុលជាប្រចាំនោះទេ ។ ផ្លូវស្ពានមួយចំនួនពុំទាន់មានផ្លាកសញ្ញា គំនូសសញ្ញា ភ្លើងសញ្ញា និងបង្គោលសញ្ញាចរាចរ ។ល។ បញ្ហានេះក៏នាំអោយមានគ្រោះថ្នាក់ចរាចរផងដែរ ។

-ការរស់នៅ ការសាងសង់លំនៅដ្ឋាន ផ្ទះសំបែង របង ឬសង់ជំរកផ្សេងៗតាមបណ្តោយដងផ្លូវជាតិ បានកើតមាននៅទូទាំងប្រទេស ជាពិសេសតាមផ្លូវជាតិ និងផ្លូវខេត្ត ដែលជាឧបសគ្គ ធ្វើអោយបាត់សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងការបើកបរ ។ កន្លែងខ្លះដោយគ្មានការត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ច បានសាងសង់ផ្ទះ ឬធ្វើរបងនៅលើផ្លូវខ្វែង ឬផ្លូវកោង ធ្វើអោយបាំងភ្នែកអ្នកបើកបរ ដែលជាហេតុធ្វើអោយមានគ្រោះថ្នាក់ចរាចរដោយចៃដន្យ ។ នៅក្នុងទីប្រជុំជនបានយកចិញ្ចើមផ្លូវសំរាប់ថ្មើរជើងមកធ្វើជាកម្មសិទ្ធិ (រំលោភលើដីចំណីផ្លូវ) សំរាប់ដាក់លក់ដូរ ចតរថយន្ត ឬដាក់សម្ភារៈផ្សេងៗ ផ្សារ

លក់ដូរភាគច្រើនស្ថិតនៅតាមបណ្តោយដងផ្លូវ ក៏ធ្វើអោយបាត់បង់សណ្តាប់ធ្នាប់ចរាចរគួរអោយកត់សំគាល់ផងដែរ ។

–កង្វះខាតចំណតយានយន្តនៅតាមទីតាំងប្រមូលផ្តុំដូចជាផ្សារ ភោជនីយដ្ឋាន សណ្ឋាគារ សាលារៀន រោងចក្រ សហគ្រាស ។ល។ បានយកចំណីផ្លូវធ្វើចំណត ងាយបង្កអោយមានការកកស្ទះ និងគ្រោះថ្នាក់ចរាចរដោយមិនអាចជៀសបាន ។ ជាក់ស្តែងឆ្លងតាមការត្រួតពិនិត្យលើទីតាំងចំនួន **៨៨** នៅរាជធានីភ្នំពេញមានទីតាំង **៦៣កន្លែង** ដែលគ្មានចំណត ហើយគ្រោះថ្នាក់ចរាចរកើតឡើងនៅតាមចំណុចទាំងនេះនៅទូទាំងប្រទេសមានរហូតដល់ **៤៨%** ។

## VI-**<u>ទិសដៅយុទ្ធសាស្ត្រ ផែនការសកម្មភាព</u>** :

សណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរជាបញ្ហាមួយដ៏សំខាន់ និងជាបញ្ហាប្រឈមដែលតម្រូវអោយមានការខិតខំប្រឹងប្រែងរួមគ្នាដើម្បីធ្វើការទប់ស្កាត់ដោយមានប្រសិទ្ធិភាព និងមាននិរន្តភាព ។ បើប្រសិនគ្មានការទប់ស្កាត់ទេនោះ ចំនួនមនុស្សស្លាប់ និងរបួសដោយសារគ្រោះថ្នាក់ចរាចរនឹងកើនឡើង ហើយតម្លៃនៃសេដ្ឋកិច្ច និងការចំណាយខាងសង្គមកិច្ចនឹងកើនឡើងមិនអាចគណនាបាន ពិសេសរបួសស្នាមដែលជិតជាមលើជនរងគ្រោះ និងក្រុមគ្រួសារគេ ។

ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍រួមរបស់អាស៊ានដែលកំណត់រហូតដល់ឆ្នាំ២០១០ កាត់បន្ថយអាត្រាស្លាប់ដោយគ្រោះថ្នាក់ចរាចរនៅត្រឹម **០៥នាក់ ក្នុងរថយន្ត ១០.០០០គ្រឿង** និងរហូតដល់ឆ្នាំ២០២០ កាត់បន្ថយអាត្រាស្លាប់ដោយគ្រោះថ្នាក់ចរាចរនៅត្រឹម **០២នាក់ ក្នុងរថយន្ត ១០.០០០គ្រឿង** ។

អង្គសិក្ខាសាលាលើកឡើងនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេលខ្លី និងរយៈពេលវែងដូចខាងក្រោម :

**១**~ក្រសួងស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ ត្រូវធ្វើផែនការសកម្មភាពអោយមានភាពស៊ីសង្វាក់គ្នា ព្រមៗគ្នានៅទូទាំងប្រទេសក្នុងការទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរផ្លូវគោក ។ នៅក្នុងទីក្រុង និងទីប្រជុំជនសំខាន់ៗត្រូវធ្វើការសិក្សាប្លង់មេ (Master Plan) ផែនការដឹកជញ្ជូន និងចរាចរអោយបានទាន់ពេលវេលា ដើម្បីដោះស្រាយបញ្ហាកកស្ទះចរាចរ និងបញ្ជៀសបាននូវគ្រោះថ្នាក់ចរាចរ ។

### **២~<u>ប្រព័ន្ធទិន្នន័យគ្រោះថ្នាក់តាមផ្លូវ</u>** :

ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធត្រូវបន្តសហការគ្នាស្រង់ទិន្នន័យគ្រោះថ្នាក់ចរាចរ និងការវិភាគអោយដឹងពីមូលហេតុនៃកត្តាទាំងឡាយដែលនាំអោយមានគ្រោះថ្នាក់ចរាចរ ដើម្បីដាក់ចេញនូវការទប់

ស្អាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរអោយមានប្រសិទ្ធិភាព ។ កិច្ចការនេះត្រូវរៀបចំជាផែនការបន្ទាន់ និងយូរអង្វែងដូចខាងក្រោម :

**២-១-ផែនការបន្ទាន់ :**

- គ្រប់ករណីគ្រោះថ្នាក់ចរាចរ នគរបាលចរាចរត្រូវបញ្ជាក់អោយច្បាស់លាស់អំពីមូលហេតុ លក្ខណ:អ្នកបើកបរ ជនរងគ្រោះ លក្ខណ:យានយន្ត....។ល។
- ត្រូវភ្ជាប់ជាមួយនូវគំរូទិដ្ឋភាពគ្រោះថ្នាក់ និងរូបថតដើម្បីអោយពត៏មានកាន់តែច្បាស់

**២-២-ផែនការយូរអង្វែង :**

- ធ្វើការបោះពុម្ពផ្សាយរបាយការណ៏ប្រចាំឆ្នាំដែលមានលក្ខណ:ទាក់ទាញការចាប់អារម្មណ៏ ស្តីពីគ្រោះថ្នាក់ដែលមានឥទ្ធិពលដល់គ្រប់មជ្ឈដ្ឋានអ្នកដឹកនាំ មន្ត្រីបុគ្គលិក អ្នកជំនួញ សិស្សសាលា និងសាធារណ:ជនទូទៅ និង
- គិតគូរបង្កើតអោយមានវិទ្យាស្ថានស្រាវជ្រាវគ្រោះថ្នាក់ចរាចរ ។

**៣-ផែនការសុវត្ថិភាព និងការរៀបចំផ្លូវ :** ត្រូវខិតខំលុបបំបាត់អោយបានកន្លែងដែលងាយបង្កអោយមានការបាត់បង់សណ្តាប់ធ្នាប់ និងគ្រោះថ្នាក់ចរាចរ :

**៣-១-ផែនការបន្ទាន់ :**

- ត្រួតពិនិត្យសុវត្ថិភាពចរាចរលើផ្លូវចាស់ និងផ្លូវថ្មីដែលបង្កអោយមានគ្រោះថ្នាក់ញឹកញាប់ ដូចជាផ្លូវស៊ុលគ្រហុក ដាក់សញ្ញាចរាចរ ភ្លើងសញ្ញាអោយបានគ្រប់គ្រាន់
- ពិចារណាបង្កើតវិធី ដើម្បីផ្តល់បរិស្ថានសុវត្ថិភាពជាង និងមានភាពអនុគ្រោះជាងដល់អ្នកប្រើប្រាស់ផ្លូវដែលងាយរងគ្រោះ
- រៀបចំកន្លែងឆ្លងថ្នល់ដល់អ្នកដំណើរ ពិសេសសិស្សសាលា មនុស្សចាស់ និងកូនក្មេង
- ធ្វើការពិនិត្យអោយម៉ឺងម៉ាត់ការដឹកជញ្ជូនលើសទម្ងន់ ត្រូវផាកពិន័យ និងមិនអោយបន្តការធ្វើចរាចរ ។

**៣-២-ផែនការយូរអង្វែង**

- បង្កើតគោលការណ៏ជាតិសំរាប់ត្រួតពិនិត្យសុវត្ថិភាពចរាចរ
- រចនា និងបង្កើតបរិស្ថានស្ពានផ្លូវ សំដៅធានាសុវត្ថិភាពជូនអ្នកប្រើប្រាស់ផ្លូវ គំនូសសញ្ញាចរាចរ ភ្លើងបំភ្លឺ ពង្រីកផ្លូវ ស្ពាន កែសំរួលផ្លូវកោងហួសបទដ្ឋានកំណត់
- ការសាងសង់ផ្លូវ សាងសង់អាគារ ត្រូវគិតគូរដល់សេចក្តីត្រូវការអ្នកប្រើប្រាស់ផ្លូវ ដូចជាផ្លូវសំរាប់អ្នកដើរ អ្នកជិះកង់ ជិះម៉ូតូ មានចំណតរថយន្តត្រឹមត្រូវ

- បង្កើនវប្បធម៌សុវត្ថិភាពក្នុងចំណោមអ្នកអាជីព តាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាល ដូចមានភ្នាក់ងាររដ្ឋាភិបាល សង្គមស៊ីវិល និងវិទ្យាស្ថានអប់រំនានា
- ពិនិត្យពិចារណាលើផែនការប្រើប្រាស់ដីធ្លីដូចជាសាលារៀន ឬផ្សារ ត្រូវសង់អោយឆ្ងាយពីទីប្រជុំជន និងជួយសហគមន៍រៀបចំកន្លែងលេង ដែលមានសុវត្ថិភាពសំរាប់កុមារ។

**៤. បទដ្ឋានសុវត្ថិភាពយានយន្ត :**

យានយន្តដែលធ្វើចរាចរលើផ្លូវជាតិត្រូវមានលក្ខណៈគ្រប់គ្រាន់ ត្រឹមត្រូវ និងត្រូវមានវិធានការហាមឃាត់ការកែឆ្នៃយានយន្តខុសច្បាប់ ។ យានយន្តដែលមិនបានធ្វើការត្រួតពិនិត្យបច្ចេកទេស ហាមឃាត់ដាច់ខាតមិនអោយធ្វើចរាចរលើដងផ្លូវ ហើយត្រូវអនុវត្តតាមបទដ្ឋានសុវត្ថិភាពយានយន្តអោយបានម៉ឺងម៉ាត់មុននឹងចេញលិខិតបញ្ជាក់ ។ ត្រូវមានការផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹងអំពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់យានយន្តកែឆ្នៃ ។

ទន្ទឹមនឹងធានានូវបទដ្ឋានសុវត្ថិភាពយានយន្ត ត្រូវជំរុញអោយយានយន្តគ្រប់ប្រភេទមានផ្លាកលេខ និងប័ណ្ណសំគាល់ត្រឹមត្រូវ ព្រោះបញ្ហានេះមិនត្រឹមតែសំរាប់សំគាល់អត្តសញ្ញាណយានយន្តនិមួយៗទាំងអស់នេះទេ ប៉ុន្តែដើម្បីរួមចំណែកក្នុងការស្រាវជ្រាវករណីប្រើប្រាស់មធ្យោបាយយានយន្តរបស់ពួកភេរវកម្ម ឬពួកប្រព្រឹត្តបទល្មើសក្នុងការធ្វើសកម្មភាពលួច ប្លន់ ចាប់ជំរិត និងបំផ្លិចបំផ្លាញសន្តិសុខជាតិថែមទៀត ។

**៥. ការអប់រំអ្នកបើកបរ និងការប្រលងយកប័ណ្ណបើកបរ :** គោលបំណងគឺបង្កើតប្រព័ន្ធមួយមានតែអ្នកបើកបរដែលមានស្មារតីល្អ យល់ដឹងច្បាប់ និងមានគុណភាព ទើបត្រូវបានអនុញ្ញាតិអោយបើកបរលើដងផ្លូវថ្នល់ ។ ឥរិយាបថអ្នកបើកបរ និងការប្រើប្រាស់យានយន្តមានសារៈសំខាន់ណាស់ ដូច្នេះត្រូវមានវិធានការដើម្បីបង្កើនសុវត្ថិភាពបើកបរនៅក្នុងអារម្មណ៍របស់អ្នកបើកបរម្នាក់ៗ ។

ត្រូវត្រួតពិនិត្យសាលារៀនបើកបរឯកជន ដោយយកចិត្តទុកដាក់ពង្រឹងសមត្ថភាពដល់គ្រូបង្ហាត់បង្រៀនបើកបរ ដោយត្រូវមានការប្រឡង និងត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពថែមទៀត ។

ត្រូវមានផែនការពង្រឹងមេរៀនបើកបរ ពង្រឹងកម្មវិធីហ្វឹកហ្វឺនដល់អ្នកបើកបរ និងបង្កើនការអប់រំសាធារណៈ និងការហ្វឹកហ្វឺនផ្នែកសុវត្ថិភាពដល់អ្នកបើកបរ និងអ្នកថ្មើរជើង ។

**៦. សង្គ្រោះបន្ទាន់សំរាប់ជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរ :** នេះក៏ជាចំណុចសំខាន់ ដើម្បីរួមចំណែកកាត់បន្ថយនូវអាត្រាស្លាប់ ។ ត្រូវយកចិត្តទុកដាក់បង្កើនបរិមាណគុណភាព និងជំនាញក្រុមសង្គ្រោះបន្ទាន់នៅតាមខេត្តនានា ក្នុងគោលដៅដើម្បីផ្តល់ការអន្តរាគមន៍ផ្នែកពេទ្យ ដើម្បីនាំជនរងគ្រោះទៅកាន់មន្ទីរពេទ្យ ។

**៧.ពង្រឹងការអនុវត្តច្បាប់** ៖ គោលបំណងសំខាន់គឺពង្រឹងច្បាប់ចរាចរ និងបទដ្ឋានក្រោមច្បាប់នានា ដើម្បីនាំមកនូវការប្រើប្រាស់ផ្លូវដោយសុវត្ថិភាព និងមានសណ្តាប់ធ្នាប់ ។ ចំណុចសំខាន់នៃការពង្រឹងការយល់ដឹងច្បាប់ចរាចរ ចាំបាច់ត្រូវធ្វើការហ្វឹកហ្វឺនដល់នគរបាលចរាចរ និងភ្នាក់ងារសុវត្ថិភាពសណ្តាប់ធ្នាប់ចរាចរ អំពីការគ្រប់គ្រងចរាចរ ការស៊ើបអង្កេតរកមូលហេតុគ្រោះថ្នាក់ ការឃាមល្បាតតាមដងផ្លូវជាតិ ផ្លូវខេត្ត និងអំពីទំនាក់ទំនងសាធារណៈ ។ ក្នុងនោះការលើកកំពស់ក្រមសីលធម៌ និងអាកប្បកិរិយាធ្វើការងាររបស់ភ្នាក់ងារអនុវត្តច្បាប់ទាំងអស់ពាក់ព័ន្ធការរក្សាសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរផ្លូវគោកគឺជាកត្តាចាំបាច់បំផុតផងដែរ ។

**ផែនការយូរអង្វែង** ៖

- ពិចារណាក្នុងការបំពាក់ឧបករណ៍សម្ភារៈទំនើបដល់មន្ត្រីនគរបាលចរាចរ ដូចជា ៖ ឧបករណ៍ត្រួតពិនិត្យជាតិអាល់កុល ឧបករណ៍ត្រួតពិនិត្យល្បឿនយានយន្ត ឧបករណ៍ត្រួតពិនិត្យកន្លែងកើតហេតុ ។ល។
- បំពាក់ឧបករណ៍ត្រួតពិនិត្យចរាចរនៅទីក្រុង និងតាមដងផ្លូវជាតិសំខាន់ៗ ។

**៨.យុទ្ធនាការផ្សព្វផ្សាយសុវត្ថិភាពចរាចរ** ៖

ទន្ទឹមនឹងការពង្រឹងការអនុវត្តច្បាប់ ការផ្សព្វផ្សាយអប់រំក៏មានតួនាទីយ៉ាងសំខាន់ ដែលជាវិធានការបង្ការមួយដ៏មានប្រសិទ្ធិភាព ។ ត្រូវមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយតាំងពីទីក្រុងរហូតដល់ជនបទ ដើម្បីអោយប្រជាពលរដ្ឋជាទូទៅយល់ដឹងអំពីច្បាប់ចរាចរផ្លូវគោក ពីភាពងាយនឹងបង្កអោយមានគ្រោះថ្នាក់ អំពីវិធានការស្វ័យការពារសុវត្ថិភាពផ្ទាល់ខ្លួន ...។ល។

ត្រូវមានការចូលរួមពីប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ទាំងទូរទស្សន៍ វិទ្យុ កាសែត ហើយត្រូវមានការផ្សព្វផ្សាយអប់រំអោយបានជាប់ជាប្រចាំ ។

**៩.ការអប់រំសុវត្ថិភាពចរាចរដល់កុមារ** ៖

គោលបំណងគឺពន្យល់ពីសុវត្ថិភាពចរាចរដល់កុមារ តាមលក្ខណៈដែលមានប្រសិទ្ធិភាព ដើម្បីសង់គ្រឹះអោយរឹងមាំសំរាប់ឥរិយាបថ និងអាកប្បកិរិយាសុវត្ថិភាពចរាចរក្នុងមួយជីវិតរបស់គេ ។

- ពិចារណាស្នើសុំគោលការណ៍រាជរដ្ឋាភិបាល ដើម្បីបញ្ចូលការអប់រំសុវត្ថិភាពចរាចរក្នុងកម្មវិធីសិក្សានៅតាមកំរិតគ្រឹះស្ថានសិក្សា ៖ មតេយ្យ បឋម និងមធ្យមសិក្សា
- ជំរុញអោយមាតា បិតា មានតួនាទីសំខាន់ក្នុងការណែនាំកូនអំពីសុវត្ថិភាពចរាចរ ។

**១០.**បន្តរកដៃគូ និងសហការជាមួយអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងទាំងផ្នែកឯកជន ដើម្បីស្វែងរកការជួយឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងសម្ភារៈ សំរាប់ធ្វើអោយវិធានការទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរកាន់តែមានប្រសិទ្ធិភាព ។ បើកទូលាយអោយវិស័យឯកជន និងអង្គការ

សង្គមស៊ីវិលផ្តល់មតិ និងទស្សនៈផ្សេងៗ គឺជាការរួមវិភាគទានដ៏ធំធេងនៅក្នុងការរៀបចំសណ្តាប់ធ្នាប់ និងទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរ ។

បន្តសហការជាមួយបណ្តាប្រទេសក្នុងតំបន់ ជាពិសេសតំបន់អាស៊ាន ដើម្បីសិក្សាលើយុទ្ធសាស្ត្រ ផែនការសកម្មភាព សុវត្ថិភាពចរាចរ ព្រមទាំងជំនួយបច្ចេកទេសផ្សេងៗ ។

## ឧបសម្ព័ន្ធទី១

### ស្ថិតិគ្រោះថ្នាក់ចរាចរពីឆ្នាំ២០០០-២០០៥

| ឆ្នាំ | ចំនួនប្រជាជន | ចំនួនយានយន្តបានចុះបញ្ជី | ចំនួនគ្រោះថ្នាក់ចរាចរ | ចំនួនជនរងគ្រោះថ្នាក់ចរាចរ | | | អាត្រាស្លាប់ | |
|---|---|---|---|---|---|---|---|---|
| | | | | ស្លាប់ | របួសស្រាល | របួសធ្ងន់ | ក្នុងយានយន្ត ១០.០០០គ្រ. | ក្នុងប្រជាជន ១០០.០០០ន. |
| 2000 | 12,014,343 | 331,904 | 2,951 | 401 | 2,391 | 1,998 | 12.08 | 3.34 |
| 2001 | 12,313,500 | 383,990 | 2,699 | 459 | 2,413 | 1,771 | 11.95 | 3.73 |
| 2002 | 12,620,604 | 410,027 | 3,335 | 535 | 3,188 | 2,113 | 13.05 | 4.24 |
| 2003 | 12,934,857 | 447,428 | 3,760 | 824 | 3,615 | 2,714 | 18.42 | 6.37 |
| 2004 | 13,256,935 | 485,612 | 4,255 | 1,042 | 3,740 | 3,833 | 21.46 | 7.86 |
| 2005 | 13,587,032 | 574,829 | 3,957 | 904 | 3,185 | 3,185 | 15.73 | 6.65 |

## ឧបសម្ព័ន្ធទី២

### ស្ថិតិគ្រោះថ្នាក់ចរាចរកើនឡើងជារៀងរាល់ឆ្នាំ១៥% ពីឆ្នាំ២០០០-២០០៥

| ល.រ | មុខសញ្ញា | ឯកត្តា | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ |
| ១ | ចំនួនគ្រោះថ្នាក់ | លើក | 2,951 | 2,699 | 3,335 | 3,760 | 4,255 | 3,957 |
| ២ | ចំនួនអ្នកស្លាប់ | នាក់ | 401 | 459 | 535 | 824 | 1,042 | 904 |
| ៣ | ចំនួនអ្នករបួសស្រាល | នាក់ | 2,391 | 2,413 | 3,188 | 3,615 | 3,740 | 3,833 |
| ៤ | ចំនួនអ្នករបួសធ្ងន់ | នាក់ | 1,998 | 1,771 | 2,113 | 2,714 | 3,185 | 3,185 |
| ៥ | ប៉ះពាល់អ្នកថ្មើរជើង | នាក់ | 93 | 79 | 438 | 688 | 803 | 455 |
| ៦ | ខូចខាតរថយន្តធុនស្រាល | គ្រឿង | 824 | 858 | 1,379 | 1,697 | 2,001 | 1,488 |
| ៧ | ខូចខាតរថយន្តធុនធ្ងន់ | គ្រឿង | 243 | 257 | 340 | 332 | 403 | 245 |
| ៨ | ខូចខាតទោចក្រយានយន្ត | គ្រឿង | 2,171 | 2,608 | 3,579 | 3,909 | 4,391 | 3,475 |
| ៩ | ខូចខាតទោចក្រយាន | គ្រឿង | | | 187 | 239 | 362 | 143 |
| ១០ | យានជំនិះផ្សេងៗទៀត | គ្រឿង | 219 | 336 | 223 | 399 | 379 | 491 |